**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

# សារលិខិត
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# ប្រធានគណបក្សប្រជាជនកម្ពុជា ផ្ញើជូនជនរួមជាតិ

**បងប្អូនជនរួមជាតិជាទីស្នេហា** !

ក្នុងនាម**គណបក្សប្រជាជនកម្ពុជា** ខ្ញុំសូមសម្តែងការគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុត ជូនបងប្អូនជនរួមជាតិនៅគ្រប់ទិសទីដែលបានផ្តល់ការគាំទ្រពេញទំហឹងចំពោះការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា និងរូបខ្ញុំនៅគ្រប់កាលៈទេសៈ ធ្វើឱ្យសម្រេចបានជោគជ័យដ៏ត្រចះត្រចង់ក្នុងការបម្រើប្រទេសជាតិ តាំងពីដំណាក់កាលសង្គ្រោះជាតិពីរបបប្រល័យពូជសាសន៍រហូតមកដល់បច្ចុប្បន្ន។

ការពិតជាក់ស្តែងបានបង្ហាញថា រយៈពេលជាង ៤៤ឆ្នាំ កន្លងទៅនេះ បន្ទាប់ពីថ្ងៃ**ជ័យជម្នះ ៧មករា** ជាប្រវត្តិសាស្ត្រលើរបបប្រល័យពូជសាសន៍ គណបក្សប្រជាជនកម្ពុជា បានផ្សារភ្ជាប់រួមសុខ រួមទុក្ខជាមួយប្រជាជន ពុះពារឆ្លងកាត់រាល់ឧបសគ្គ ដឹកនាំប្រទេសឱ្យចេញផុតពីស្ថានភាពដែលវិនាសខ្ទេចខ្ទី ឈានមកដល់ដំណាក់កាលអភិវឌ្ឍន៍លើគ្រប់វិស័យប្រកបដោយមោទនភាពជាទីបំផុត។ កម្ពុជាបានប្រែក្លាយពីវាលពិឃាតនៃរបបប្រល័យពូជសាសន៍ ពីសមរភូមិនៃសង្គ្រាមដ៏រ៉ាំរ៉ៃ ពីការបែកបាក់ជាតិ និងពីទឹកដីដែលរចនាសម្ព័ន្ធសង្គមត្រូវបំផ្លាញដល់ឫសគល់ ទៅជាទឹកដីដែលប្រជាជនបានរស់នៅយ៉ាងសុខដុមរមនាក្នុងសន្តិភាព ឯកភាពជាតិ អធិបតេយ្យ បូរណភាពទឹកដី និងប្រជាធិបតេយ្យ ហើយកំពុងរួមសាមគ្គីគ្នាក្រោមដំបូលរដ្ឋធម្មនុញ្ញតែមួយ យកអស់កម្លាំងកាយ កម្លាំងចិត្តដើម្បីបន្តកសាង និងការពារមាតុភូមិ។ **នេះជាការផ្លាស់ប្តូរដ៏ធំធេងរបស់ព្រះរាជាណាចក្រកម្ពុជា។**

នៅក្នុងនីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ដែលមានរូបខ្ញុំជានាយករដ្ឋមន្ត្រី បានការពារយ៉ាងរឹងមាំនូវសន្តិភាព ស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម ដែលបានធានាដល់ការរស់នៅដ៏សុខសាន្តរបស់ប្រជាជន ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងការពង្រឹងពង្រីកប្រជាធិប-តេយ្យ។ សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋត្រូវបានគោរព ការពារ និងលើកស្ទួយ។ វិស័យសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ អប់រំ សុខាភិបាល ការងារ និងវិស័យផ្សេងៗទៀតកាន់តែមានភាពរីកចម្រើន។ ផ្លូវ ស្ពាន ប្រព័ន្ធធារាសាស្ត្រ ទឹកស្អាត អណ្តូងទឹក ភ្លើងអគ្គិសនី ប្រព័ន្ធព័ត៌មាន រោងចក្រ កសិដ្ឋាន សំណង់តូចធំ មណ្ឌលពាណិជ្ជកម្ម សាលារៀន មន្ទីរពេទ្យ វត្តអារាម ។ល។ ត្រូវបានកសាងពង្រីកទាំងនៅទីក្រុង ជនបទ និងតំបន់ព្រំដែន។

ពេលត្រូវប្រឈមនឹងការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលបានដឹកនាំការប្រយុទ្ធទប់ស្កាត់ជំងឺដ៏កាចសាហាវនេះប្រកបដោយជោគជ័យ ការពារបានអាយុជីវិតប្រជាជន រក្សាបានលំនឹងជីវភាព និងលំនឹងសេដ្ឋកិច្ច និងធ្វើឱ្យសេដ្ឋកិច្ចជាតិអាចងើបឡើងវិញយ៉ាងឆាប់រហ័សក្រោយវិបត្តិជំងឺកូវីដ-១៩។ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវវិធានការជាច្រើនដើម្បីលើកស្ទួយផលិតកម្ម បង្កើនការងារ និងមុខរបររបស់ប្រជាជន ពង្រឹងពង្រីកសេវាសាធារណៈ

ពង្រឹងយុត្តិធម៌សង្គម និងលើកកម្ពស់ការគាំពារសង្គមសម្រាប់ប្រជាជនគ្រប់រូប ជាពិសេសប្រជាជនក្រីក្រ និងងាយរងគ្រោះ។ ទន្ទឹមនឹងភាពរឹងមាំនៃកត្តាផ្ទៃក្នុងជាតិ កិត្យានុភាពកម្ពុជាកាន់តែបានលើកកម្ពស់នៅលើឆាកអន្តរជាតិ ជាពិសេស តាមរយៈជោគជ័យនៃការរៀបចំ និងដឹកនាំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០-៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនានា ការរៀបចំអង្គរសង្ក្រាន្ត, ការរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២, ការអនុវត្តនយោបាយការបរទេសឯករាជ្យដោយផ្អែកលើច្បាប់ និងស្មារតីមនុស្សធម៌ដ៏ធំធេង បានធ្វើឱ្យកេរ្តិ៍ឈ្មោះរបស់កម្ពុជាកាន់តែលេចត្រដែតឡើង។

ឆ្លងតាមសមិទ្ធផលដ៏ថ្លៃថ្លាទាំងនេះ បានបង្ហាញច្បាស់ថាព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងធ្វើដំណើរទៅមុខលើមាគ៌ាដ៏ត្រឹមត្រូវប្រកបដោយក្តីសង្ឃឹមជឿជាក់ ឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង។

*បងប្អូនជនរួមជាតិជាទីស្នេហា!* នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ត្រូវនឹងថ្ងៃអាទិត្យ ៦កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ខាងមុខនេះ ជាថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ដែលនឹងបង្កើតរាជរដ្ឋាភិបាលសម្រាប់នីតិកាលថ្មី ដើម្បីដឹកនាំប្រទេសរយៈពេល ៥ឆ្នាំ តទៅមុខទៀត។ អាស្រ័យហេតុនេះ សូមបងប្អូនជនរួមជាតិ ដែលបានឃើញច្បាស់ហើយនូវសកម្មភាព សមិទ្ធផលលើគ្រប់វិស័យ និងកម្មវិធីនយោបាយដ៏ត្រឹមត្រូវរបស់គណបក្សប្រជាជនកម្ពុជា សូមអញ្ជើញទៅបោះឆ្នោត និង**បោះឆ្នោតគាំទ្រគណបក្សប្រជាជនកម្ពុជា ដែលមានរូបសញ្ញាទេវតាបាចផ្កា និងមានលេខរៀងទី ១៨** នៅលើសន្លឹកឆ្នោតឱ្យបានគ្រប់គ្នាកុំបីខាន ដើម្បីជានាការថែរក្សាសន្តិភាព និងការអភិវឌ្ឍប្រទេសជាតិជាបន្តទៀត។

**គណបក្សប្រជាជនកម្ពុជា** ប្តេជ្ញាអនុវត្តកម្មវិធីនយោបាយដែលបានប្រកាសជូនជនរួមជាតិឱ្យបានសម្រេចជោគជ័យ បង្កើតសមិទ្ធផលធំៗថ្មីៗទៀតជូនជាតិ និងធ្វើឱ្យប្រជាជនមានជីវភាពកាន់តែសម្បូរសប្បាយ រស់នៅយ៉ាងសុខដុមរមនាក្នុងសង្គម ប្រកបដោយការគោរពតម្លៃមនុស្ស ប្រជាធិបតេយ្យ សេរីភាព និងយុត្តិធម៌។

ខ្ញុំសូមប្រសិទ្ធពរជូនបងប្អូនជនរួមជាតិទាំងអស់ បានប្រកបនូវពុទ្ធពរ និងពរទាំងប្រាំប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ៕

ថ្ងៃសៅរ៍ ១៤កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០២៣

**ប្រធានគណបក្សប្រជាជនកម្ពុជា**

**ហ៊ុន សែន**